**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : **អង់គ្លេស**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Dec-2012, 16:00
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ ជាមួយឧបសម្ព័ន្ធសម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី TCW-247 ជាមុន ជាមួយឧបសម្ព័ន្ធសម្ងាត់ ក**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក គង់ សំអុន
លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

១. អនុលោមតាម វិធាន៨៧(៤), ៥៣(៤) និង ២១(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាសុំការអនុញ្ញាតដើម្បីដាក់ទៅក្នុងសំណុំរឿងងនូវ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដោយសង្ខេបមួយ ដែលបានធ្វើឡើងជាមួយសាក្សី **TCW-247** នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ (កំណត់ហេតុស្តាប់ចម្លើយសាក្សី)[1]។ ឯកសារនេះមាននៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ Database របស់សហព្រះរាជអាជ្ញា ដែលជាផ្នែកមួយនៃការត្រៀមរៀបចំសម្រាប់ការសួរដេញដោលសាក្សីរូបនេះ។

២. បទសម្ភាន៍ខ្លីនេះដែលបានធ្វើឡើងកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៧ គឺជាផ្នែកនៃស៊ើបអង្កេតដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងរយៈពេលនៃកិច្ចស៊ើបសួរបឋមរបស់ខ្លួននៅក្នុងសំណុំរឿងនេះ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីនេះមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ ប៉ុន្តែវាមានមិនលើសពីពីរទំព័រទេ។ គេគ្មានកំណត់ហេតុណាផ្សេងទៀតនៃការស្តាប់ចម្លើយនេះទេ។

៣. ទោះបីជា វិធានផ្ទៃក្នុងរបស់ អវតក មិនបានចែងច្បាស់ៗតម្រូវឲ្យសហព្រះរាជអាជ្ញាបង្ហាញជូននូវរាល់ចម្លើយពីមុនៗទាំងអស់របស់សាក្សីនានា ដែលអង្គជំនុំជម្រះសាលាដំបូងបានកោះហៅដើម្បីឲ្យមកផ្តល់សក្ខីកម្មនោះក្តី ក៏សហព្រះរាជអាជ្ញាបានប្រកាន់នូវទស្សនៈយល់ឃើញថា ការបង្ហាញជូនបែបនេះតោងតែមានការប្រុងប្រយ័ត្ន និងឲ្យស្របទៅតាមបទដ្ឋានអន្តជាតិ[2] ។ ក្នុងការឆ្លើយតបទៅនឹងសំណើសុំការណែនាំទាក់ទងទៅនឹងចម្លើយនានាដែលចាត់ទុកជាការសំងាត់បំផុត ដែលបានផ្តល់ឲ្យដោយសាក្សីដែលមានសក្តានុពលនានានៅក្នុងពេលសវនាការលើសំណុំរឿងផ្សេងទៀត អង្គជំនុំជម្រះបានសំរេចថា ការបង្ហាញជូននូវចម្លើយសាក្សីទាំងនេះ (ជាលើកដំបូងជូនអង្គជំនុំជម្រះ ) គឺជាការនាំមកនូវផលប្រយោជន៍ដល់ការបញ្ជាក់ពីការពិត[3] ហើយដែលបន្ទាប់មកទៀតបានត្រៀមរៀបចំឲ្យមានជាស្រេចសំរាប់ផ្តល់ជូនដល់គ្រប់ភាគីទាំងអស់[4]។

---

[1] ឧបសម្ព័ន្ធសម្ងាត់ ក - ERN 00089733-00089734។

[2] ឯកសារលេខ **E233/1** សំណើរបស់សព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងស្តីពីកំណត់ហេតុនៃការធ្វើសម្ភាសន៍សាក្សី TCW-428 របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៥ កញ្ញា ២០១២,ឯកសារលេខ E233/1 ។ ឯកសារលេខ **E127** ការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង របស់សហព្រះរាជអាជ្ញាន្តរជាតិនូវកំណត់ហេតុ នៃការធ្វើសម្ភាសន៍សាក្សីនៃសំណុំរឿងលេខ០០២ នៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក ដែលចាត់ទុកជាការសំងាត់បំផុត ភ្ជាប់មកជាមួយផង, ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១, កថាខណ្ឌទី១២ ។ ការដែលតម្រូវឲ្យបង្ហាញជូននូវចម្លើយសាក្សីនានាកាលពីមុនៗមកនេះ គឺមានចែង *ក្នុងចំណោមវិធានដទៃៗទៀតជាច្រើន* នៅក្នុងវិធាន៧៦ នៃវិធានស្តីពីវិធាននិងភស្តុតាង (RoPE) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងនៅក្នុងវិធាន៦៦ នៃ RoPE របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី។

[3] ឯកសារលេខ **E127/4** អនុស្សរណៈដែលមានចំណងជើងថា “ការបង្ហាញជូននូវចម្លើយសាក្សីសំរាប់សាក្សីទាំងឡាយដែលអាចនឹងផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ ០០២,” ចុះថ្ងៃទី២៤ មករា ២០១២។

[4] ឯកសារលេខ **E127/6** អនុស្សរណៈដែលមានចំណងជើងថា “ការដាក់ចំណាត់ងថ្នាក់ឡើងវិញទៅលើចម្លើយរបស់សាក្សីដែលអាចផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២,” ចុះថ្ងៃទី២៩ កុម្ភៈ ២០១២។

៤. ខណៈដែលសហព្រះរាជអាជ្ញា មិនមានការយល់ឃើញថា កំណត់ហេតុស្ដាប់ចម្លើយសាក្សីនេះមានព័ត៌មានដែលអាចមានលក្ខណៈដោះបន្ទុកយ៉ាងណាក៏ដោយ ក៏សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា វាគួរតែមានផលប្រយោជន៍សម្រាប់យុត្តិធម៌ ដោយការដាក់វាចូលទៅក្នុងសំណុំរឿង និងធ្វើឲ្យអង្គជំនុំជម្រះ និងគ្រប់ភាគីទាំងអស់មានលទ្ធភាពអាចធ្វើការពិនិត្យឡើងវិញបាន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញារង | | |